UNAKRT
United Nations Assistance to the Khmer Rouge Trials

# អនុស្សរណៈអន្តរការិយាល័យ - សម្ងាត់

ផ្ញើជូន៖ លោកចៅក្រម គង់ ស្រីម
ប្រធានអង្គជំនុំជម្រះតុលាការកំពូល
លោកចៅក្រម និល ណុន
ប្រធានអង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-Apr-2016, 14:06
CMS/CFO: Sann Rada

ចម្លងជូន៖ លោក Volker Nerlich មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង
លោក Kenneth Roberts មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

មកពី៖ លោកចៅក្រម Michael Bohlander សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស")

កម្មវត្ថុ៖ **បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស និងការពន្យល់អំពីវិធីសាស្ត្រដែលបានអនុវត្ត**

១. ខ្ញុំផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល នូវលទ្ធផលនៃគម្រោងវិភាគបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ដើម្បីជាប្រយោជន៍នៃយុត្តិធម៌។ អនុស្សរណៈនេះពណ៌នាអំពីវិធីសាស្ត្រដែលបានយកមកប្រើប្រាស់ ដើម្បីរៀបចំបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ (“បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១” ឬ “បញ្ជី”)។

២. ការរៀបចំបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ បានចំណាយពេល ២៤ ខែ ចាប់ពីខែ មេសា ឆ្នាំ ២០១៤ រហូតដល់ខែ មីនា ឆ្នាំ ២០១៦។ បញ្ជីនេះត្រូវបានរៀបចំដោយអ្នកស្រី ហិន សុធានី (Hin Sotheany) ទីប្រឹក្សាផ្នែកវិភាគ ក្រោមការគ្រប់គ្រងរបស់លោក Hiroto Fujiwara ជាប្រធានក្រុមវិភាគ។

៣. ឯកសារនានាដែលត្រូវបានយកមកប្រើប្រាស់ដើម្បីចងក្រងជាបញ្ជីឈ្មោះអ្នកទោសនៅ

មន្ទីរ ស-២១ គឺជា ឯកសារទាំងអស់ដែលបន្សល់ទុកតាំងពីសម័យខ្មែរក្រហម ដែលត្រូវបានប្រមូលពីទួលស្លែង និងពីមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam")។ ឯកសារទាំងនេះគ្របដណ្ដប់អំឡុងពេលពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។

៤. សរុបជារួម ឯកសារចំនួន ១៣៣៨៣ ត្រូវបានយកមកពិនិត្យ ហើយអាចត្រូវបានបែងចែកជាប្រភេទឯកសារខាងក្រោម៖

ក. អ្នកទោសចូលមន្ទីរ ស-២១
 ១. អ្នកទោសចូលមន្ទីរ ស-២១ ប្រចាំថ្ងៃ
 ២. អ្នកទោសចូលមន្ទីរ ស-២១ ប្រចាំខែ
 ៣. អ្នកទោសចូលមន្ទីរ ស-២១ ប្រចាំឆ្នាំ
 ៤. អ្នកទោសចូលមន្ទីរ ស-២១ កាលបរិច្ឆេទណាមួយ និង
 ៥. អ្នកទោសចូលមន្ទីរ ស-២១ ដែលបែងចែកតាមផ្នែក

ខ. ប្រវត្តិរូបអ្នកទោសមន្ទីរ ស-២១

គ. អ្នកទោសមន្ទីរ ស-២១ ដែលត្រូវបានរៀបចំដោយបុគ្គលិកមន្ទីរ ស-២១ ទាក់ទិននឹងស្ថានភាពអ្នកទោស ("បញ្ជីក្ដាប់អ្នកទោសប្រចាំថ្ងៃ")

ឃ. អ្នកទោសនៅមន្ទីរ ស-២១ ដែលត្រូវបានសួរចម្លើយ ("បញ្ជីសួរចម្លើយ")

ង. អ្នកទោសនៅមន្ទីរ ស-២១ ដែលយកទៅសម្លាប់

៥. អ្នកស្រី ហ៊ិន សុធាវី (Hin Sotheany) ទីប្រឹក្សាផ្នែកវិភាគ បានពិនិត្យឯកសារទាំងនោះដកស្រង់ព័ត៌មានដែលពាក់ព័ន្ធ និងបញ្ចូលព័ត៌មានទាំងនោះទៅក្នុងតារាង Excel។ ព័ត៌មានពាក់ព័ន្ធដែលត្រូវបានជ្រើសរើសគឺ៖

ក. ឈ្មោះអ្នកទោស (ភាសាខ្មែរ និងអង់គ្លេស)

ខ. ឈ្មោះហៅក្រៅ (បើមាន)

គ. ភេទ

ឃ. អាយុ

ង. សមាជិកគ្រួសារដែលពីមុននៅមន្ទីរ ស-២១

ច. ប្ដី/ប្រពន្ធនៅមន្ទីរ ស-២១

ឆ. កាលបរិច្ឆេទចូលមន្ទីរ ស-២១

ជ. តួនាទីដែលមាន នៅពេលចាប់ខ្លួន

ឈ. ទីកន្លែងចាប់ខ្លួន

ញ. កាលបរិច្ឆេទចាប់ខ្លួន

ដ. ទីតាំងឃុំខ្លួននៅក្រៅមន្ទីរ ស-២១

ឋ. កាលបរិច្ឆេទសម្លាប់

ឌ. លេខយោងប្រភពឯកសារ (លេខ ERN លេខឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា លេខឯកសារនៅទួលស្លែង)

៦. មានតែអ្នកទោសដែលអាចផ្ទៀងផ្ទាត់បានជាមួយនឹងឯកសារសម័យខ្មែរក្រហមទេ ដែលត្រូវបានបញ្ចូលទៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១។ សម្រាប់សំណេរជាភាសាអង់គ្លេសនូវឈ្មោះជាភាសាខ្មែរ និងទីតាំង ប្រព័ន្ធសំណេរជាភាសាអង់គ្លេសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានយកមកប្រើប្រាស់។ មានការយកចិត្តទុកដាក់ជាទីបំផុតដើម្បីបញ្ចៀសការបញ្ចូលឈ្មោះអ្នកទោសជាន់គ្នា។

៧. នៅពេលបញ្ចប់ការរៀបចំបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ ឈ្មោះចំនួន ១៥.១០១ នាក់ ត្រូវបានបញ្ចូលក្នុងបញ្ជីនោះ ដែលកើនឡើងយ៉ាងច្រើនលើសចំនួនពីមុនដែលមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ការិយាល័យសហព្រះរាជអាជ្ញា (ជាទូទៅគេហៅថា "បញ្ជីរបស់ ក.ស.ព ដែលបានកែសម្រួល")។